# រដ្ឋធម្មនុញ្ញកម្ពុជាត្រូវបានគេរំលោភបំពានទាំងកំរោល
# ដោយគ្មានទណ្ឌកម្មអ្វីសោះឡើយ

យោងតាមសេចក្តីថ្លែងការណ៍របស់អ្នកនាំពាក្យក្រសួងយុត្តិធម៌លោកកើត រិទ្ធ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ការបកស្រាយនានាទៅ លើមាត្រា៨០នៃរដ្ឋធម្មនុញ្ញស្តីអំពីអភ័យឯកសិទ្ធិអ្នកតំណាងរាស្ត្រគឺជាកំហុសឆ្គងផ្លូវច្បាប់មួយគួរអោយព្រួយបារម្ភណ៍។

១. មាត្រា១៣៦ថ្មីបញ្ជាក់យ៉ាងច្បាស់ថាក្រុមប្រឹក្សាធម្មនុញ្ញមានកិត្យានុកូលភាពនិងសមត្ថកិច្ចការពារធានារដ្ឋធម្មនុញ្ញជាអ្នកបកស្រាយ រដ្ឋធម្មនុញ្ញជាដើម។ ដូច្នេះទាំងលោកនាយករដ្ឋមន្ត្រី ទាំងមេអេស៊ីយូទាំងអ្នកនាំពាក្យក្រសួងយុត្តិធម៌ ។ល។និង។ល។មិនមានសមត្ថកិច្ចក្នុងការបកស្រាយរដ្ឋធម្មនុញ្ញជំរុញអោយតុលាការដែលជាអ្នកពង្រឹងវិជ្ជាជីវៈច្បាប់និងនគរបាលដែលជាអ្នកពង្រឹងអោយមានការអនុវត្ត ច្បាប់ធ្វើទាំងបំពានទៅលើរដ្ឋធម្មនុញ្ញបានទេ។ អ្នកបកស្រាយទាំងនោះគឺជាអ្នកបំពានរដ្ឋធម្មនុញ្ញទាំងកំរោល។

២. លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានជ្រៀតជ្រែកប្រព័ន្ធតុលាការដែលជាអ្នកពង្រឹងវិជ្ជាជីវៈ ម្តងហើយម្តងទៀត ឧទាហរណ៍ដូចជា លោកប្រើប្រាស់សំដីសាធារណៈអោយចោទប្រកាន់ករណីរឿងស្ពាននាគ ករណីរឿងការបញ្ចេញមតិរបស់សមាជិកព្រឹទ្ធសភាហុង សុខហួ ករណីលោកសម រង្ស៊ី ករណីសមាជិកសភាអ៊ុំ សំអាន និងករណីសមាជិកសង្គមស៊ីវិលថ្មីៗនេះជាដើម យើងឃើញថាតុលាការចាត់ វិធានការណ៍ភ្លាម។ ការប្រើ ប្រាស់អំណាចដែលអាចបណ្តាលអោយមានការភ័យខ្លាចនិងបាត់បង់មុខវិជ្ជាជីវៈរបស់មន្ត្រីតុលាការគឺជាការ រំលោភអំណាចដែលមានប្រ សិទ្ធិភាព។ ហើយមន្ត្រីតុលាការដែលបោះបង់មុខវជ្ជាជីវៈនិងកាតព្វកិច្ចរបស់ខ្លួនជំនួយដោយឥទ្ធិពលពីខាង ក្រៅ គួរត្រូវដកចេញពីតំណែងនិងដាក់ទោសទណ្ឌ។

៣. ក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែន មាត្រាសំខាន់ៗនៅក្នុងរដ្ឋធម្មនុញ្ញមិនត្រូវបានយកមកអនុវត្តន៍ឡើយ ឧទាហរណ៍ដូចជាសមាជជាតិនិងព្រះមហាក្សត្រជាប្រធានឧត្តមប្រឹក្សាការពារជាតិ ជាដើម។ មានមាត្រាជាច្រើន ទៀតដូចជាមាត្រា៥១ស្តីអំពីការមិនអាចជ្រៀតជ្រែកទៅលើអំណាចទាំងបី មាត្រា៣១ស្តីអំពីអនុវត្តន៍តាមកតិកាសញ្ញាអន្តជាតិត មាត្រា ៥២ដល់មាត្រា៥០ ស្តីអំពីការគោរពសិទ្ធិពលរដ្ឋជាដើមមិនត្រូវបានលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ខិតខំពង្រឹងឡើយ។

៤. មិនមែនគ្រាន់តែរូបរន្តបុគ្គលអ្នកមានអំណាចបកស្រាយនិងអនុវត្តន៍ទាំងរំលោភទៅលើរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ រដ្ឋាភិបាលលោកនាយក រដ្ឋមន្ត្រីហ៊ុន សែន បានអនុមត្តិច្បាប់ជាច្រើនដែលផ្ទុយពីរដ្ឋធម្មនុញ្ញ ហើយនាំគ្នាយកច្បាប់ទាំងនោះមកអនុវត្តន៍តំរូវទៅតាមចំណង់ចំណូល ចិត្តរបស់ខ្លួន។

៥. ដល់ពេលហើយដែលលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ត្រូវបញ្ឈប់នយោបាយបំពារបំពានលើរដ្ឋធម្មនុញ្ញនេះ។ អាយុជីវិតរបស់ប្រទេស កម្ពុជានិងសុខដុមរម្មនីយកម្មនៃប្រជាជនរបស់ប្រទេសនេះ គឺស្ថិតលើស្មារតីគោរពរដ្ឋធម្មនុញ្ញអោយពេញលេញទាំងអស់គ្នា។

# ជំពូកទី ១២ ថ្មី

# អំពីក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ១៣៦ ថ្មី.-**

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

# រដ្ឋធម្មនុញ្ញ

**មាត្រា ៨០.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីរាយការណ៍ ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួន នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខ ០៤ អ.យ.ឃ

## ដីកាបង្គាប់ឲ្យចាប់ខ្លួន

យើង **ស៊ី ចន្ទណ្ណី** តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ មាត្រា ២៧ មាត្រា ១៥៦ មាត្រា ៤៩៦ និងមាត្រា ៤៩៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០-០៨-២០០៧។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣២ (ខ) ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨៥ (ខ) ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍។

-បានឃើញ ពាក្យសុំអនុវត្តសាលដីកាស្ថាពរ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥ របស់លោក **គារ សាវុធ** មេធាវីតំណាងដោយអាណត្តិឲ្យ **ឯកឧត្តម ហោ ណាំហុង** ។

ក្រោយពីបានពិនិត្យឃើញថា:

-នាមត្រកូល-នាមខ្លួន **សម រង្ស៊ី** ភេទប្រុស អាយុ ៦០ឆ្នាំ ជនជាតិខ្មែរ មុខរបរ ប្រធានគណបក្សសង្គ្រោះជាតិ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ៨៧៦ ផ្លូវជាតិលេខ ២ ក្រុមទី ៣១ ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ត្រូវបានចោទប្រកាន់ពីបទ: ***បរិហារកេរ្តិ៍ជាសាធារណៈ និងញុះញង់ឲ្យមានការរើសអើង*** ប្រព្រឹត្តនៅសារមន្ទីរជើងឯក សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៨ តាមមាត្រា **៣០៥** មាត្រា **៤៩៤** និងមាត្រា **៤៩៦** នៃក្រមព្រហ្មទណ្ឌ ។

### យល់ឃើញថា

-តាមអំណាចសាលក្រម និងសាលដីកាស្ថាពរខាងលើបានចូលជាស្ថាពរ មានប្រសិទ្ធិភាពអនុវត្តហើយ ។

-ឈ្មោះ **សម រង្ស៊ី** ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០(ប្រាំបីលាន)រៀល ហើយសាលាឧទ្ធរណ៍បានសម្រេច ចំណាយសំណុំរឿងចេញពីបញ្ជីក្តីសាលាឧទ្ធរណ៍ តាមសាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ តែឈ្មោះ **សម រង្ស៊ី** ពុំទាន់បានអនុវត្តទោសនៅឡើយ ។

### ហេតុដូច្នេះសម្រេច

១-ឲ្យចាប់ខ្លួនឈ្មោះ **សម រង្ស៊ី** ដែលមានអត្តសញ្ញាណខាងលើនេះ តាមអំណាចសាលដីកាស្ថាពរលេខ ១៧ ក្រ៥.ប ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ។

២-បង្គាប់មកកងកម្លាំងសាធារណៈឲ្យស្រាវជ្រាវចាប់ខ្លួន និងនាំខ្លួនទណ្ឌិតឈ្មោះ **សម រង្ស៊ី** យកទៅអនុវត្តទោសនៅពន្ធនាគារនៃក្រសួងមហាផ្ទៃ ។

៣-គ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់ត្រូវសហការអនុវត្តឲ្យមានប្រសិទ្ធភាពល្អ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ វិច្ឆិកា ឆ្នាំ ២០១៥

**តំណាងអយ្យការ**

ស៊ី ចន្ទណ្ណី
ព្រះរាជអាជ្ញារង


លោក នី ចរិយា
លោក ណៃ វង្សដា
លោក យី សុខសាន្ត
លោកស្រី លឹម មុន្នី
លោក នី សុខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

# សេចក្តីថ្លែងការណ៍

**ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ** យល់ឃើញថា រាល់ការចេញដីកាកោះហៅតំណាងរាស្ត្រ ដែលមានអភ័យឯកសិទ្ធិសភា ពីសំណាក់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គឺជាការប្រើអំណាចដោយរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រ ដែលធានាការពារដោយមាត្រា៨០នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា៨០នៃរដ្ឋធម្មនុញ្ញ បានចែងថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន សមាជិកណាមួយនៃរដ្ឋសភានឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។ សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវបានដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល"។

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ នឹងមិនទៅតាមដីកាកោះរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលរំលោភបំពានច្បាប់នោះឡើយ។

**ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ** ស្នើសុំឲ្យបញ្ឈប់ជាបន្ទាន់នូវការចេញដីកាកោះហៅតំណាងរាស្ត្រ ដែលមានអភ័យឯកសិទ្ធិសភា ពីសំណាក់ស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ហើយត្រូវគោរពរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ដើម្បីធានាការអនុវត្តច្បាប់ឲ្យបានខ្ជាប់ខ្ជួន ស្របតាមគោលការណ៍នៃនីតិរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦
**ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ**

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖*
*លេខទូរស័ព្ទ៖ 012 858 857*

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៦៤សយក..........

# សេចក្តីថ្លែងការណ៍

កាលពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ នេះ ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិបានចេញសេចក្តីថ្លែងការណ៍មួយ ដោយបានបញ្ជាក់ថា តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ នឹងមិនទៅតាមដីកាកោះរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយបានចោទប្រកាន់ថា ការចេញដីកាកោះហៅតំណាងរាស្ត្រដែលមានអភ័យឯកសិទ្ធិសភាពីសំណាក់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញនេះ គឺជាការប្រើអំណាចដោយរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រ ដែលធានាការពារដោយមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ មានការសោកស្តាយយ៉ាងខ្លាំង ដែលក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិ ដែលជាអ្នកធ្វើច្បាប់ បានធ្វើការបកស្រាយដោយខ្វះការយល់ដឹងត្រឹមត្រូវអំពីច្បាប់ និងនីតិវិធីរបស់អង្គការអយ្យការ និងតុលាការ ព្រមទាំងបានធ្វើការចោទប្រកាន់ដោយមិនត្រឹមត្រូវ និងមានលក្ខណៈជាការមួលបង្កាច់ទៅលើស្ថាប័នអនុវត្តច្បាប់ ដែលបានអនុវត្ត ការងារ និងសមត្ថកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ ការចេញសេចក្តីថ្លែងការណ៍របស់ក្រុមសមាជិកសភាគណបក្សសង្គ្រោះជាតិនេះ ឆ្លើយតបទៅនឹងដីកាកោះហៅរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ជំនួសមុខឱ្យរូបវន្តបុគ្គលដែលជាកម្មវត្ថុនៃដីកាកោះហៅ គឺជាទង្វើដែលមានចរិតជាការដាក់សំពាធទៅលើអំណាចតុលាការ ដែលជាអំណាចឯករាជ្យធានាការពារដោយច្បាប់ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ សូមជម្រាបជូនសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាបថា អភ័យឯកសិទ្ធិសភា ដែលមានចែងក្នុងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាការពារអ្នកតំណាងរាស្ត្រពី **ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន** និង**ការឃុំខ្លួន** ចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត **វៀរលែងតែក្នុងករណីបទល្មើសជាក់ស្តែង**។ ខ្លឹមសារទាំងស្រុងនៃមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម ៖

*"តំណាងរាស្ត្រ មានអភ័យឯកសិទ្ធិសភា។*

*តំណាងរាស្ត្រណាក៏ដោយ មិនអាចត្រូវបាន**ចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន** ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួននោះឡើយ។*

***ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន**សមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា **វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង**។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច។*

មហាវិថីសម្តេចសុធារស ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 217 841

*សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីភាគបីនៃសមាជិករដ្ឋសភាទាំងមូល។*

*ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល។*

ផ្អែកតាមមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាខាងលើនេះ អភ័យឯកសិទ្ធិសភាការពារតំណាងរាស្ត្រ ចំពោះកិច្ចនីតិវិធីចំនួន ៤ តែប៉ុណ្ណោះ គឺ **ការចោទប្រកាន់** **ការចាប់ខ្លួន** **ការឃាត់ខ្លួន** និង **ការឃុំខ្លួន** ប៉ុន្តែ ពុំមានចំណុចណាមួយក្នុងមាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ ឬក្នុងច្បាប់ដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលការពារតំណាងរាស្ត្រពី **ការកោះហៅ**របស់អង្គការអយ្យការ ឬ**ការកោះហៅ** ដោយតុលាការ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ រដ្ឋប្បវេណី និងសំណុំរឿងផ្សេងៗទៀតឡើយ។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ សូមបញ្ជាក់ជូនសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបថា អំណាចតុលាការ គឺជាអំណាចឯករាជ្យដែលធានាការពារដោយច្បាប់ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ហើយការប្រើអំណាច ដោយអនុវត្តតាមផ្លូវច្បាប់ គឺជាការអនុវត្តជាធម្មតា ស្របគោលការណ៍នៃនីតិរដ្ឋ នៅក្នុងសង្គមប្រជាធិបតេយ្យសេរី។

អ្នកនាំពាក្យក្រសួងយុត្តិធម៌ សូមអំពាវនាវដល់គណបក្សនយោបាយ សង្គមស៊ីវិល បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាទុកកិច្ចការងារនៃការអនុវត្តច្បាប់ខាងលើនេះ ជូនទៅស្ថាប័នអនុវត្តច្បាប់ ដើម្បីអនុវត្តមុខការ និងសមត្ថកិច្ចរបស់ខ្លួន ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ជៀសវាងការធ្វើសកម្មភាពដោយថាហេតុណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តច្បាប់ ដើម្បីរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ ដែលជាបំណងប្រាថ្នាទាំងអស់គ្នា នៅក្នុងសង្គមប្រជាធិបតេយ្យសេរី។ ៚

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦

**អ្នកនាំពាក្យក្រសួងយុត្តិធម៌**

**មាត្រា ៥២២.-** បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ

ការផ្សព្វផ្សាយមុនសេចក្ដីសម្រេចជាស្ថាពររបស់តុលាការ នូវអត្ថាធិប្បាយ ដោយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការដែលទទួលបណ្ដឹង ដើម្បីជះឥទ្ធិពលទៅលើសេចក្ដីសម្រេចរបស់តុលាការ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

**មាត្រា ៥២៣.-** បទធ្វើឱ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ

អំពើរិះគន់លិខិត ឬសេចក្ដីសម្រេចរបស់តុលាការ ក្នុងគោលដៅបង្កឱ្យមានភាពវឹកវរដល់សណ្ដាប់ធ្នាប់សាធារណៈ ឬក៏បង្កឱ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

អំពើដែលមិនអនុវត្តសេចក្ដីសម្រេចរបស់តុលាការ ត្រូវផ្ដន្ទាទោសដូចគ្នានឹងទោសដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើ ។

# ក្រមព្រហ្មទណ្ឌ

# ក្រមនីតិវិធីព្រហ្មទណ្ឌ

## ផ្នែកទី ២

## ការអនុវត្តបណ្តឹងអាជ្ញា

**មាត្រា ៤០.** – ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ។

ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម ។

ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។